# វ៉ាក់សាំងជំងឺ COVID-19៖ ប្រការដែលត្រូវដឹង

| តើខ្ញុំអាចទទួលបានការចាក់វ៉ាក់សាំងនៅកន្លែងណា? | តើខ្ញុំធ្វើការណាត់ជួបដោយរបៀបណា? |
| --- | --- |
| អ្នកផ្តល់សេវាសុខភាពរបស់អ្នក | ទូរសព្ទទៅអ្នកផ្តល់សេវារបស់អ្នក ឬធ្វើការណាត់ជួបតាមអនឡាញ |
| គ្លីនិកចាក់វ៉ាក់សាំងទ្រង់ទ្រាយធំ | ចូលទៅកាន់គេហទំព័ររបស់យើង៖ **vaccinelocator.doh.wa.gov/**<br><br>ឬទូរសព្ទទៅលេខ 1-800-525-0127 បន្ទាប់មកចុចសញ្ញា #។ មានជំនួយផ្នែកភាសាសម្រាប់ផ្តល់ជូន។ |
| ឱសថស្ថានតាមមូលដ្ឋាន | |
| គ្លីនិកបណ្តោះអាសន្ន ឬ គ្លីនិកតាមសហគមន៍ | វាមានលក្ខណៈផ្សេងៗគ្នា។ អ្នកអាចនឹងដឹងអំពីគ្លីនិកនេះពីមិត្តភក្តិ ឬសមាជិកសហគមន៍។ សាកសួរពួកគេអំពីរបៀបចុះឈ្មោះ។ |

## តើខ្ញុំគួរយកអ្វីមកជាមួយទៅកាន់ ការណាត់ជួបចាក់វ៉ាក់សាំងរបស់ខ្ញុំ?

អ្នកអាចនឹងត្រូវបានគេសួររកឯកសារមួយចំនួនដូចខាងក្រោម ប៉ុន្តែអ្នកមិនចាំបាច់

ត្រូវតែផ្តល់ឯកសារទាំងនោះទេ៖

- អត្តសញ្ញាណប័ណ្ណ
- ប័ណ្ណធានារ៉ាប់រង
- លេខសន្តិសុខសង្គម



**អ្នកមិនចាំបាច់ទាល់តែជាពលរដ្ឋអាមេរិក ទើបទទួលបានវ៉ាក់សាំងនោះទេ។**

**ពួកគេនឹងមិនសួរ អំពីស្ថានភាពអន្តោប្រវេសន៍របស់អ្នកទេ។**

**ទិន្នន័យផ្ទាល់ខ្លួននឹងត្រូវបានប្រើប្រាស់សម្រាប់គោលបំណងសុខភាពសាធារណៈតែប៉ុណ្ណោះ។**

## តើវ៉ាក់សាំងនេះមានតម្លៃប៉ុន្មាន?

អ្នកទទួលបានវ៉ាក់សាំងនេះដោយឥតគិតថ្លៃ។ អ្នកមិនគួរត្រូវបានគិតប្រាក់ ឬទទួលបានវិក្កយបត្រទូទាត់ទេ។

## តើខ្ញុំចាំបាច់ត្រូវចាក់វ៉ាក់សាំងលើកទីពីរដែរឬទេ?

វ៉ាក់សាំងមួយចំនួនមានពីរដូស។ វាត្រូវចំណាយពេលប្រហែលពីរសប្តាហ៍ ក្រោយពេលអ្នកបានទទួលការចាក់វ៉ាក់សាំងគ្រប់ចំនួន ដើម្បីទទួលបានការការពារល្អបំផុត។ មនុស្សមួយចំនួនអាចនឹងត្រូវការដូសជំរុញ។

| | |
| --- | --- |
| Pfizer-BioNTech | 2ដូស មានចន្លោះពេលចាក់ 21ថ្ងៃ |
| Moderna | 2ដូស មានចន្លោះពេលចាក់ 28ថ្ងៃ |
| Johnson & Johnson | 1ដូស |

**សម្រាប់ព័ត៌មានបន្ថែម**

ចូលទៅកាន់៖ **COVIDVaccineWA.org** ឬ **DOH.WA.GOV/Coronavirus**

ទូរសព្ទទៅ៖ **1-800-525-0127** រួចចុចសញ្ញា #។ មានជំនួយផ្នែកភាសាសម្រាប់ផ្តល់ជូន។

Vaccinate WA

CovidVaccineWA.org

## តើផលរំខានមានអ្វីខ្លះ?

អ្នកទំនងជាអាចនឹងមានផលរំខាន។

**ក្នុងរាងកាយរបស់អ្នកទាំងមូល៖**



- អស់កម្លាំង
- ឈឺក្បាល
- ឈឺសាច់ដុំ
- ព្រឺរងា
- គ្រុនក្តៅ
- ចង្អោរ

**លើដៃត្រង់កន្លែងដែលអ្នកបានចាក់ថ្នាំ៖**



- មានការឈឺចាប់
- ឡើងក្រហម
- ហើម

សម្រាប់វ៉ាក់សាំងពីរដូស ផលរំខានអាចនឹងធ្ងន់ធ្ងរជាងមុន បន្ទាប់ពីការចាក់ថ្នាំលើកទីពីរ ។

ទូរសព្ទទៅលេខ 911 ប្រសិនបើអ្នកមានប្រតិកម្ម អាលែកហ្ស៊ី។ អ្នកអាចចុះឈ្មោះក្នុងកម្មវិធី V-safe ដើម្បីរាយការណ៍អំពីផលរំខាននានា៖ **vsafe.cdc.gov**។

## តើវ៉ាក់សាំងមួយប្រភេទល្អប្រសើរជាងវ៉ាក់សាំងប្រភេទផ្សេងទៀតដែរឬទេ?

យើងសូមណែនាំឱ្យចាក់វ៉ាក់សាំងជំងឺ COVID-19 សេរី mRNA (Pfizer-BioNTech ឬ Moderna) ជំនួសវ៉ាក់សាំង Johnson & Johnson (J&J) ដែលចាក់តែមួយដូស។

យ៉ាងណាក៏ដោយ វ៉ាក់សាំង J&J នៅតែអាចប្រើបាន ប្រសិនបើអ្នកចង់ចាក់វ៉ាក់សាំងនេះ។ សូមពិភាក្សាជាមួយអ្នកផ្តល់ការថែទាំសុខភាពអំពីជម្រើសរបស់អ្នក។



## តើវ៉ាក់សាំងជំងឺ COVID-19 មានមុខងារអ្វីខ្លះ?



វ៉ាក់សាំង COVID-19 បង្ហាត់រាងកាយរបស់អ្នកឲ្យបង្កើតការការពារទល់នឹងជំងឺ ដែលការពារអ្នកមិនឲ្យមានជំងឺ។

## តើវ៉ាក់សាំងទាំងនេះមានសុវត្ថិភាពដែរឬទេ?

បាទ/ចាស។ គ្រប់វ៉ាក់សាំងទាំងអស់ ត្រូវបានធ្វើតេស្តទៅលើមនុស្ស**រាប់ម៉ឺននាក់**។

ពួកវាត្រូវបានបង្ហាញឲ្យឃើញពីប្រសិទ្ធភាពសម្រាប់មនុស្សគ្រប់ជាតិសាសន៍នានាជាច្រើន និងអ្នកដែលមានស្ថានភាពសុខភាពដូចជាជំងឺធាត់ជ្រុល ជំងឺទឹកនោមផ្អែម ជំងឺបេះដូង ជំងឺថ្លើម និងវីរុសហ៊ីវ។





Department of Health (ក្រសួងសុខាភិបាល) ពិនិត្យមើលរបាយការណ៍សុវត្ថិភាពជាប្រចាំដើម្បីធ្វើឲ្យប្រាកដថាគ្មានក្តីបារម្ភផ្នែកសុវត្ថិភាពណាមួយឡើយ។

## ហេតុអ្វីបានជាខ្ញុំគួរតែទទួលការចាក់វ៉ាក់សាំង?

ការទទួលការចាក់វ៉ាក់សាំង នឹងជួយឲ្យអ្នករក្សាបានសុវត្ថិភាពនៅកន្លែងការងារ និងចេញទៅខាងក្រៅជាមួយមិត្តភក្តិនិង គ្រួសារសាជាថ្មីទៀតបាន។

អ្នកនឹងមិនមានជំងឺធ្ងន់ធ្ងរ ចូលសម្រាកពេទ្យ ឬស្លាប់ដោយសារជំងឺ COVID-19 នោះទេ។



**DOH 348-804 December 2021 Khmer**

Washington State Department of Health

ដើម្បីស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទូរសព្ទទៅលេខ 1-800-525-0127។ អតិថិជនគថ្លង់ ឬពិបាកក្នុងការស្តាប់ សូមទូរសព្ទទៅលេខ 711 (Washington Relay) ឬអ៊ីម៉ែល civil.rights@doh.wa.gov